ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២១

នៅក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖

### ១- មុខងារនីតិកម្ម

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់៖

១-សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា១៩ថ្មី មាត្រា៨២ថ្មី មាត្រា១០៦ថ្មី(មួយ) មាត្រា១១៩ថ្មី និងមាត្រា១៣៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យស្តីពី ការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ

៣-សេចក្តីព្រាងច្បាប់ស្តីពី ភាពជាដៃគូរវាងរដ្ឋ និងឯកជន

- បានរៀបចំចាត់ចែងជូនគណៈកម្មការទី២ និងទី៦ ព្រឹទ្ធសភា ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល តាមប្រព័ន្ធវីដេអូ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ ពីរាជរដ្ឋាភិបាល និងរដ្ឋសភា ព្រមទាំងចាត់ចែងតាមនីតិវិធី



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

- បានទទួលព្រះរាជក្រឹត្យ សេចក្ដីសម្រេច សេចក្ដីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន១១ច្បាប់

-បានសិក្សាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីលើសេចក្ដីព្រាងច្បាប់ចំនួន០៣ច្បាប់

- បានធ្វើកំណត់បង្ហាញអនុក្រឹត្យ របាយការណ៍ និងលិខិតផ្សេងៗចំនួន១១ច្បាប់

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចៗ

**២- មុខងារតំណាង**

- បានផ្ដល់សេវាជូន**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ សមាជិក សមាជិកាក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក និងឃុំ-សង្កាត់ នៅខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តកំពត និងខេត្តព្រះសីហនុ

- បានផ្ដល់សេវាជូន**ឯកឧត្ដមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ថ្វាយកម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** ក្នុងឱកាសខួបលើកទី៩ឆ្នាំ នៅមណ្ឌបតម្កល់ព្រះបរមរូប

- បានរៀបចំបែបបទ ផ្ដល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ការដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសការអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាប្រក្រតីក្នុងបរិបទនៃជំងឺកូវីដ-១៩ ការងារចាក់វ៉ាក់សាំងបង្ការជូនប្រជាពលរដ្ឋ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗ ព្រមទាំងបានចូលរួមក្នុងពិធីផ្សេងៗចំនួន៩៩លើក នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កោះកុង កែប តាកែវ កណ្ដាល ព្រៃវែង ស្វាយរៀង ក្រចេះ កំពង់ចាម ត្បូងឃ្មុំ កំពង់ឆ្នាំង កំពង់ធំ បាត់ដំបង សៀមរាប បន្ទាយមានជ័យ និងខេត្តឧត្ដរមានជ័យ

- ឯកឧត្ដមអគ្គលេខាធិការព្រឹទ្ធសភា បានធ្វើបាឋកថាមូលដ្ឋានគ្រឹះស្ដីពី "តើមន្ត្រីរបស់សភាចូលរួមការអនុវត្តជាក់ស្ដែងដូចម្ដេចខ្លះ?" ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានទទួលពាក្យបណ្ដឹងចំនួន០៤ករណី ផ្ញើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន០៤ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន០៤ករណី និងកំពុងពិនិត្យសិក្សាចំនួន០៣ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន០៤ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្ដឹងពីស្ថាប័នពាក់ព័ន្ធចំនួន០១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន០២ករណី

- បានចាត់ចែងបញ្ជូនសារប្រកាសគាំទ្រគំនិតផ្ដួចផ្ដើមរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការស្នើធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធ ដើម្បីឈានទៅកំណត់ឱ្យឥស្សរជនកំពូលរបស់ជាតិក្នុងមុខតំណែងប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី និងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានសញ្ជាតិខ្មែរតែមួយគត់ និងសារលិខិតជូនពរ**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឱកាសចម្រើនជន្មាយុ

- បានផលិតទស្សនាវដ្ដីប្រចាំខែតុលា ឆ្នាំ២០២១ ចំនួន៨០០ក្បាល។

**៣- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំទីកន្លែង និងផ្ដល់សេវាក្នុងពិធីជំនួបពិភាក្សាការងារជូន**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយឯកឧត្តម WANG YANG ប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន នៃសាធារណរដ្ឋប្រជាមានិតចិន តាមព័ន្ធវីដេអូ

- បានរៀបចំចាត់ចែងជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំនានារួមមាន៖ កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាទទួលបន្ទុកកិច្ចសហប្រតិបត្តិការជាមួយអន្តរសភាកម្ពុជា-ឡាវ-វៀតណាម(CLV) ដើម្បីពិនិត្យ និងពិភាក្សាបូកសរុបរបាយការណ៍លទ្ធផលចូលរួមសន្និសីទលើកទី៨ នៃគណៈកម្មការកិច្ចការបរទេសនៃសភា(CLV) ស្ដីពី ការជំរុញភាពជាដៃគូសភា ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការឆ្លើយតបចំពោះកូវីដ-១៩ នៅក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម, កិច្ចប្រជុំពិនិត្យលើសេចក្ដីព្រាងសេចក្ដីប្រកាស ASEP11 (Zero Draft), កិច្ចប្រជុំក្រុមសមាជិកព្រឹទ្ធសភាស្ដីពី ការត្រៀមចូលរួមកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ ការពង្រឹងភាពជាដៃគូសភាដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងសម័យ និងក្រោយវិបត្តិកូវីដ-១៩, កិច្ចប្រជុំសភាពិភពលោកលើកទី១ ស្ដីពី ការសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ក្រោមមូលបទការកែប្រែបញ្ហាប្រឈមនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ទៅជាឱកាសសម្រាប់សភា ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ផ្សាយចេញពីទីក្រុងហ្សាកាតា សាធារណរដ្ឋឥណ្ឌូនេស៊ី, កិច្ចប្រជុំគណៈកម្មការកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍នៃសភាប្រើភាសាបារាំង (APF) ផ្សាយចេញពីទីក្រុងប៉ារីស សាធារណរដ្ឋបារាំង និង

ចូលរួមវេទិកាអាស៊ី-អឺរ៉ុប ស្តីពី " ស្ត្រី សន្តិភាព សន្តិសុខ" តាមប្រព័ន្ធវីដេអូ

- បានចងក្រងកម្រងកម្មវិធីជំនួបភ្ញៀវអន្តរជាតិ (ឆ្នាំ២០១៤-២០២១)

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតឥណ្ឌា, ស្ថានទូតហ្វីលីពីន, ស្ថានទូតចិន, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ច(CDC), វិទ្យាស្ថានសាន់វ៉ាយស៍, វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (NIPTICT), ក្រុមហ៊ុនKOHA និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហា-រូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ

### ៤- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បានរៀបចំបែបបទ និងសម្របសម្រួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ (ដូសទី១ និងទី២) ជូនកូនចៅរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំត្រួតពិនិត្យ និងពិភាក្សាលើគម្រោងបែងចែក និងការប្រើប្រាស់ថវិកាព្រឹទ្ធសភា ឆ្នាំ២០២២

- បានប្រជុំគណៈកម្មការលទ្ធកម្មអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំត្រួតពិនិត្យការងារសំខាន់ចំពោះមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំស្តីពី គោលការណ៍ដំឡើងឋានន្តរស័ក្តិ ថ្នាក់តាមកម្រិតសញ្ញាបត្រមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្រប នឹងដំណាក់កាលថ្មីៗ

#### ៤.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានស្នើសុំគម្រោងគាំទ្របណ្ណាល័យអេឡិចត្រូនិចលើកទី២

- បានរៀបចំតារាងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានវិជ្ជមានកូវីដ-១៩ (កំពុងព្យាបាល និងជាសះស្បើយ)ចំនួន០៣នាក់ និងបានធ្វើចត្តាឡីស័កចំនួន០៦នាក់

- បានទទួលលិខិតចូលចំនួន២០១ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៤២ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីធានា ឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានបើកប្រាក់បៀវត្សប្រចាំខែតុលា ឆ្នាំ២០២១ និងប្រាក់ឧបត្ថម្ភផ្សេងៗជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខា-

ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែតុលា ឆ្នាំ២០២១

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន០២វគ្គ មានសិក្ខាកាមចូលរួមចំនួន១៨នាក់

- បានរៀបចំបើកវគ្គបណ្តុះបណ្តាលភាសាអង់គ្លេស (Pre-Intermediate) ក្រោមការគាំទ្ររបស់ស្ថានទូតហ្វីលីពីនប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានរៀបចំវគ្គបណ្តុះបណ្តាល(APF)ស្តីពី ស្វយ័តភាពរបស់សភា

- បានបញ្ចប់ការសាងសង់អគារ១ខ្នង កម្ពស់៣ជាន់ សម្រាប់ជាការិយាល័យធ្វើការរបស់នាយកដ្ឋានព័ត៌មានវិទ្យា

- បានសង់រោងដែកសម្រាប់ដាក់ម៉ាស៊ីនភ្លើង និងកន្លែងដាក់ធុងសំរាម នៅខាងក្រោយអគារជប៉ុន

- បានជួសជុលកែលម្អពង្រីកសាលបណ្ណាល័យព្រឹទ្ធសភា

- បានធ្វើដងទង់ជាតិអ៊ីណុក និងឈើ ដាក់នៅសាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សាលសាឡុងធំ និងនៅបន្ទប់ប្រជុំរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា

- បានកែលម្អសួនច្បារជុំវិញអគារក្រហម កាត់តម្រឹមស្មៅ និងផ្កានានាចំនួន១៣ប្លង់

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានជួសជុលបណ្តាញលូ ដាក់ខ្នោះមុខទឹកភ្លៀង និងបូមស្តារលាងសម្អាតប្រព័ន្ធលូនៅក្នុងបរិវេណព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក ត្រួតពិនិត្យដំណើរយន្ត ត្រួតពិនិត្យសត្វកណ្តៀរ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១០៦គ្រឿង/លើក

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែតុលា ឆ្នាំ២០២១ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

**៤.២-ការងារស្រាវជ្រាវ៖**

- បានតាមដានការកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាល និងសិក្សាស្រាវជ្រាវការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកល

នៃជំងឺកូវីដ-១៩

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន២៨អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែតុលា ឆ្នាំ២០២១ ចំនួន០២ច្បាប់។

**២.៣-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Laptop Ipad Smart Phone និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ចំនួន២២គ្រឿង ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន០២លើក។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន៨៥ប្រធានបទ

- បានចាត់ចែងការផលិតខ្សែវីដេអូអំពីប្រវត្តិអគារព្រឹទ្ធសភាក្នុងបរិវេណវិមានរដ្ឋចំការមន

- បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅតាមជំនាញផ្សេងៗចំនួន០២ក្បាល

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៥២លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២២លើក

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានល្អ និងរលូន។

**២.៤-ការងារពិធីការ៖**

- បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២០លើក

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន១៣ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែតុលា ឆ្នាំ២០២១ ចំនួន០១ច្បាប់។

II-**លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧៥ច្បាប់

- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ ចងបដា និងពាក្យស្លោកចំនួន ១៤លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៨ច្បាប់ ស្មើនឹង៣០នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣២៤លើក

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣៦សំណើ

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៨លើក មានអ្នកចូលរួមចំនួន២៨៦នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២៧០លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន២,០៥៥ច្បាប់ អស់ក្រដាសចំនួន២១,៥៥៨សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន៨៩លើក ស្មើនឹង១២៣នាក់ៗ បានជួសជុល ប្តូរប្រេងម៉ាស៊ីន និងសំបកកង់រថយន្តចំនួន ០៥គ្រឿង

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន០២លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និង Telegramចំនួន២,០៨០លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន០៩លើកៗ

**III-ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២១**

*-ការគំរាមកំហែងបន្តនៃជំងឺកូវីដ-១៩ ដែលបណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតា (Delta) ដែលកំពុងបន្តអូសបន្លាយ បានបង្កផលប៉ះពាល់ជាអវិជ្ជមាន សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន*

*-អនុវត្តវិធានសុខាភិបាលថ្មីតាមរយៈការចាក់វ៉ាក់សាំងលើកទី៣ (ដូសជំរុញ) បន្តអនុវត្តវិធានការ "៣ការពារ ៣កុំ" ពាក់ម៉ាស់ ធ្វើតេស្តពេលចាំបាច់ និងវិធានការចាំបាច់ផ្សេងៗទៀត (ដាក់ឱ្យនៅដាច់ដោយឡែក វឹចត្តាឡីស័ក) ប្រឆាំងនឹងជំងឺកូវីដ-១៩ ក្នុងពេលវេលាថ្មីដែលមេរោគប្រភេទដែលតា(Delta) កំពុងរាលដាល និងបន្តយកចិត្តទុកដាក់ធ្វើការងារមនុស្សធម៌ក្នុង និងក្រៅស្ថាប័នឱ្យបានទាន់ពេលវេលា៖*

*+យកចិត្តទុកដាក់តាមដានសុខភាពរបស់សមាជិកព្រឹទ្ធសភា*

*+យកចិត្តទុកដាក់តាមដានសុខភាព លក្ខខណ្ឌការងារ និងជីវភាពទូទៅក្នុងក្របខណ្ឌស្ថាប័នទាំងមូល*

*+ត្រៀមលក្ខណៈនៃការវិលត្រលប់មកកាន់ភាពប្រក្រតីនៃការអនុវត្តមុខងារស្នូលទាំង៣៖ មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង*

*+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន*

*+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ*

*+សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព*

*-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៩ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ។ វត្តមានមន្ត្រី បុគ្គលិកត្រូវឈរលើគោលការណ៍សមមូលនៃទំហំការងារ៖*

*+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា*

-ដំណើរឆ្ពោះទៅកាន់មូលដ្ឋានរបស់ព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាល ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ ដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០២២

-បង្កើនគុណភាព និងប្រសិទ្ធភាពផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួង ស្ថាប័ននានា

-ត្រៀមសហការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៧ និងទី៨ ឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៤ មានរបៀបវារៈដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

២-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអាស៊ានស្តីពី ការពង្រឹងយន្តការដោះស្រាយវិវាទ

៤-បញ្ហាផ្សេងៗ។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំអញ្ជើញចូលរួមពិធីបុណ្យជាតិសំខាន់ៗ៖ បុណ្យកឋិន, ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិ, ពិធីបុណ្យឯករាជ្យជាតិ, ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា៖

+ត្រៀមពិធីសម្ពោធសមិទ្ធផលវត្តព្រែកជ្រៃ នៅខណ្ឌដង្កោ និងវត្តកោះមេត្តាពោធិវង្ស នៅខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា ការងារពិធីការជាតិ និងស្ថាប័ន កម្មវិធីជំនួប កម្មវិធីផ្លូវការ និងសាសនា ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩៖

+ផ្តោតអាទិភាពលើការរៀបចំប្រជុំ (ASEP) និង(AIPA) ដែលសភាកម្ពុជាជាម្ចាស់ផ្ទះ។ សហការរៀបចំវគ្គសិក្សាដែលព្រឹទ្ធសភាត្រូវរៀបចំជាមួយ (APF) ដើមខែវិច្ឆិកា។ តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU)ជាមួយឥណ្ឌា និងប៉ាគីស្ថាន កម្មវិធីវិទ្យាស្ថានក្រសួងការបរទេស និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ឡើងវិញជាមួយដៃគូសំខាន់ៗរបស់(PCA) ជាមួយរដ្ឋសភា-ព្រឹទ្ធសភាបារាំង លេខាធិការដ្ឋាន(APF) លេខាធិការដ្ឋាន(AIPA) និង(KPI) ព្រមទាំងដៃគូថ្មីមួយចំនួនទៀត (វិទ្យាស្ថានសភាឡាវ)។ តាមដានការអនុវត្តជំនួយចិនសម្រាប់បណ្ណាល័យអេឡិចត្រូនិច និងគម្រោងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) តាមការអនុវត្តកម្មវិធីបណ្តុះបណ្តាលជាបន្តបន្ទាប់

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ

-ការឈានទៅបង្កើតក្រុមជាតិ(ASEP) រវាងរដ្ឋសភា និងព្រឹទ្ធសភា។ ការធ្វើបច្ចុប្បន្នភាពក្រុមនានាក្រោយការផ្លាស់ប្តូរសមាជិកព្រឹទ្ធសភា

-ត្រៀមបែបបទចាំបាច់សម្រាប់ការរៀបចំប្រជុំ និងការត្រៀមប្រជុំ(ASEP) នាខែវិច្ឆិកា

-ត្រៀមចូលរួមមហាសន្និបាត( IPU) លើកទី១៤៣ នៅប្រទេសអេស្ប៉ាញ

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការ

ចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ (IPU, APF, AIPA, ASEP...)។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ការបញ្ចប់ផែនការការងារដំណាច់ឆ្នាំ បូកសរុប និងលើកទិសដៅឆ្នាំថ្មី

-ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ស្តីពី កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាមួយរាជបណ្ឌិត្យសភាកម្ពុជា

-រយៈពេលបង្កើនការរឹតខ្សែក្រវ៉ាត់ ដោយវិធានការវិចារណកម្មថវិកា ក្នុងឆមាសទី២ ឆ្នាំ២០២១, ការកសាងថវិកាឆ្នាំថ្មី២០២២ ដោយគិតដល់តម្រូវការក្នុងអំឡុងពេលបោះឆ្នោតថ្នាក់ឃុំ-សង្កាត់ ក្នុងឆមាសទី១ ឆ្នាំ២០២២៖ សម្ពាធនៃតម្រូវការអនុវត្តភាពតំណាងរបស់ព្រឹទ្ធសភា អនុវត្តស្វែងរកជំនួយចិន និងដៃគូ ដើម្បីចាប់ផ្តើមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័ន បន្ទាប់ពីមជ្ឈមណ្ឌលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) ត្រូវបានសាងសង់រួច

-ការត្រៀមរៀបចំជួសជុល កែលម្អអគារអតីតនាយកដ្ឋានព័ត៌មានវិទ្យា(ICT) ក្រោមអគារក្រហមក្រោយពេលនាយកដ្ឋាននេះរើចូលអគារថ្មី

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់២ខែចុងឆ្នាំ ឱ្យបានទាន់ពេលវេលា

-យកចិត្តទុកដាក់អនុវត្តគោលការណ៍ 3E's ដោយផ្តោតលើការងារជាអាទិភាព សំខាន់ចាំបាច់ និងបន្ទាន់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ធៀតបញ្ចូលការប្រើប្រាស់គ្រឿងយន្តអគ្គិសនី និងពង្រីកការបំភ្លឺដោយថាមពលព្រះអាទិត្យ ដើម្បីថែរក្សាធម្មជាតិបៃតង កាត់បន្ថយចំណាយ និងការប្រើកម្លាំងមនុស្ស ហើយចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-អនុវត្តការងារ២ខែចុងឆ្នាំ តាមបរិបទកូវីដ-១៩ ដោយសម្រេចឱ្យបាននូវការងារជាអាទិភាព កសាងថវិកាឆ្នាំ២០២២ លើកផែនការ និងកម្មវិធីការងាររបស់ស្ថាប័ន និងគ្រប់អង្គភាពឆ្នាំ២០២២។ ការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងការទូទាត់ថវិកាប្រចាំឆ្នាំ ត្រូវអនុវត្តទាន់ពេលវេលា ដោយស្មារតីទទួលខុសត្រូវ៖

+របាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភាឆ្នាំ២០២១ និងវិភាជន៍គម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២២ ដើម្បីឆ្លងយោបល់សម្រេចក្នុងរចនាសម្ព័ន្ធរដ្ឋបាល និងនយោបាយ

+ការបោះពុម្ពទិនានុប្បវត្តិ ប្រតិទិន ប័ណ្ណរថយន្ត ត្រូវជានាគុណភាព និងបរិមាណសមស្របកម្មវិធីបុណ្យ និងកម្មវិធីផ្សេងៗទៀតត្រូវជានាការអនុវត្តឱ្យបានទាន់ពេលវេលា

+ជំរុញការកសាងខ្សែវីដេអូអំពីប្រវត្តិទីស្ថានអគារប្រវត្តិសាស្ត្ររបស់ព្រឹទ្ធសភា

-ធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស តម្រូវការ និងការប្រឈម៖ គោលការណ៍តមជ្រើសរើសថ្មីរហូតឆ្នាំ២០៣០ ការតម្លើងកាំប្រាក់ មុខតំណែង សន្ទស្សន៍បៀវត្សត្រូវរក្សាស្ថានភាពដដែលរហូតមានការណែនាំថ្មី

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការអនុវត្តផែនការបណ្តុះបណ្តាលធនធានមនុស្សតាមកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា៖

+ថវគ្គជាមួយភាគីឥណ្ឌា

+វគ្គជាមួយ (PCA)

+វគ្គភាសាអង់គ្លេស ភាសាបារាំង និងថៃជាមួយក្រសួងការបរទេស

+វគ្គជាមួយលេខាធិការដ្ឋាន (APF) ខេត្តវិច្ឆិកា

-បញ្ចូលប្រើបច្ចេកវិទ្យា ឧបករណ៍បច្ចេកទេសប្រើអគ្គិសនី (រថយន្តបោសសម្អាត រថយន្តសម្រាប់ឡើងទីខ្ពស់ រថយន្តប្រមូលសំរាម និងរថយន្តលាងសម្អាតផ្លូវ) ការបង្កើយអគារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) ការចាប់ផ្តើមការដ្ឋានបណ្ណាល័យអេឡិចត្រូនិច ការគ្រប់គ្រងសំរាម និងផ្លាស្ទិក ការរក្សាអនាម័យ និងសួនតាមរបៀបថ្មី របៀបគិត រស់នៅ និងធ្វើការតាមគន្លងថ្មីក្រោមការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងតាមរបៀបប្រែប្រួលអាកាសធាតុ (ដែលកាន់តែក្តៅ កខ្វក់ និងក្រទឹក) ធម្មជាតិប្រែប្រួលតាមរយៈគម្រោងតូចៗ (Pilot Project)។ បច្ចេកវិទ្យា-ព័ត៌មានកខ្វក់(ឧបករណ៍ ហេដ្ឋារចនាសម្ព័ន្ធ ស្តុកទិន្នន័យ)។ ជំងឺកូវីដ-១៩ មានការគំរាមកំហែងខ្លះដល់បរិស្ថានផងដែរ។ ពិចារណាការប្រើប្រាស់កម្លាំងពលកម្មឱ្យបានសមស្របដំណាក់កាលថ្មីដែលមានការប្រែប្រួលជារៀងរាល់ថ្ងៃ

-ការប្រជុំពីចម្ងាយ ការធ្វើការពីចម្ងាយ និងការរៀនសូត្រពីចម្ងាយ គឺជាឧបករណ៍ថ្មីវិធីសាស្ត្រថ្មីក្នុងបរិបទកូវីដ-១៩ ហើយអាចនៅបន្តក្រោយជំងឺកូវីដ-១៩

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ទំនាក់ទំនង និងជំរុញសុំការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិន គម្រោងជំនួយចិនក្នុងការសាងសង់ និងបំពាក់សម្ភារមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានវិទ្យា(ICT)

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានា។ល។)

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-បន្តការផលិតខ្សែវីដេអូអំពីប្រវត្តិអគារព្រឹទ្ធសភាក្នុងបរិវេណវិមានរដ្ឋចំការមន។

## IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែតុលានេះ ស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ មានសភាពធូរស្រាលឡើងវិញ រាជរដ្ឋាភិបាលកម្ពុជាបានបើកដំណើរការប្រទេសពេញលេញឡើងវិញលើគ្រប់វិស័យ។ ក្នុងបរិបទនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវខិតខំបត់បែនតាមគន្លងថ្មី ដោយរៀនរស់ជាមួយកូវីដ-១៩ និងខិតខំផ្តល់សេវាលើការងារជាអាទិភាព ដើម្បីទ្រទ្រង់លើមុខងាររបស់ព្រឹទ្ធសភាប្រព្រឹត្តទៅបានដោយរលូន។ ស្របពេលជាមួយគ្នានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០១លើក។ ចំពោះមុខងារតំណាង បានបំពេញមុខងាររបស់ខ្លួនបានយ៉ាងល្អប្រសើរតាមតម្រូវការចាំបាច់ជាក់ស្តែងប្រកបដោយភាពទទួលខុសត្រូវតាមមុខសញ្ញារៀងៗខ្លួន ដោយផ្តោតការយកចិត្តទុកដាក់ចុះតាមមូលដ្ឋាន ដើម្បីជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន ឈ្វេងយល់អំពីសុខទុក្ខដោះស្រាយបញ្ហាប្រឈម ព្រមទាំងចែកអំណោយជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តាឡីស័ក នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។ លើមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំ និងចាត់ចែងការជួបពិភាក្សាការងារជាមួយប្រធានសភា

ប្រឹក្សានយោបាយប្រជាជនចិន និងកិច្ចប្រជុំវេទិកាអាស៊ី-អឺរ៉ុប, (ASEP), (APF) តាមប្រព័ន្ធវីដេអូ។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។

ថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១

**អគ្គលេខាធិការ**

អ៊ុំ សារិទ្ធ